00918005

002/19-09-2007-ECCC/TC
E1/172

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 06 / 2013
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ពុធ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣

**សវនាការពិភាក្សាលើផលវិបាក កើតចេញពីសេចក្តីសម្រេច**

**របស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៣**

**សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៥៩**

រៀបចំដោយ: សែ កុលវុឌ្ឍី និង Matteo CRIPPA

| |
|---|
| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ឌុច ផារី, លោកស្រី Faiza ZO UAKRI, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ត, លោក Andrew CAYLEY, លោក Dale LYSAK, |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), ខៀវ សំផន |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael G. Karnavas |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី ស៊ិន សុវ៉ន, លោក សំ សុគង់, លោក វ៉ែន ពៅ, លោកស្រី Lyma NGUYEN, លោកស្រី Beini YE |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ គ្មាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី Susan LAMB, លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី, លោក Elburg VAN BOETZELAER |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៤៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី នួន ជា អៀង សារី និង ខៀវ សំផន | មេធាវីការពារក្តី នួន ជា | ០៩.១០ | ១០.០០ |
| | មេធាវីការពារក្តី អៀង សារី | ១០.០០ | ១០.៣៥ |
| | | ១១.០៧ | ១១.៤០ |
| | មេធាវីការពារក្តី ខៀវ សំផន | ១១.៤០ | ១២.០៨ |
| | អង្គជំនុំជម្រះ | ១៣.៣៥ | ១៤.២៥ |
| ការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ដោយសហព្រះរាជអាជ្ញា និង មេធាវីនាំមុខ | សហព្រះរាជអាជ្ញា | ១៤.២៦ | ១៤.៤១ |
| | | ១៥.០៣ | ១៥.២៣ |
| | មេធាវីនាំមុខ | ១៥.២៣ | ១៥.៤៨ |
| ការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ | មេធាវីការពារក្តី នួន ជា | ១៥.៤៩ | ១៥.៥៥ |

| | | | |
|---|---|---|---|
| សហព្រះរាជអាជ្ញា និងមេធាវីនាំមុខដោយមេធាវីការពារក្តី | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ១៥.៥៥<br>១៦.០៤ | ១៦.០៤<br>១៦.១២ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការជំនួសលោកស្រី ចៅក្រម Cartwright ដោយលោកស្រីចៅក្រម Fenz**

ដោយសារតែមូលហេតុផ្ទាល់ខ្លួន លោកស្រីចៅក្រម Cartwright មិនអាចមានវត្តមាននៅក្នុងដំណើរការសវនាការសម្រាប់សប្តាហ៍នេះទេ។ ផ្អែកតាមវិធាន ៧៩.៤ លោកស្រីចៅក្រម Fenz នឹងជំនួសលោកស្រីចៅក្រម Cartwright រហូតដល់លោកស្រីចៅក្រម អាចចូលមកបំពេញការងារបានដូចធម្មតាវិញ (សូមមើលសេចក្តីសម្រេចថ្ងៃចន្ទ ទី ១៨ ខែ កុម្ភះ ឆ្នាំ ២០១៣ នៅក្នុងកំណត់ហេតុសវនាការថ្ងៃទី ១៨ ខែ កុម្ភះ ឆ្នាំ ២០១៣)។

**ការធ្វើសេចក្តីសន្និដ្ឋានដោយក្រុមមេធាវីការពារក្តី នួន ជា អៀង សារី និង ខៀវ សំផន**

មេធាវីការពារក្តី នួន ជា អៀង សារី និង ខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងបញ្ហា ៩ ដែលបានស្នើដោយអង្គជំនុំជម្រះនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះចុះថ្ងៃទី ១២ ខែ កុម្ភះ ឆ្នាំ ២០១៣។

**ការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី ដោយសហព្រះរាជអាជ្ញា**

សហព្រះរាជអាជ្ញា និងមេធាវីនាំមុខ បានឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានដែលធ្វើដោយក្រុមមេធាវីការពារក្តី នួន ជា អៀង សារី និង ខៀវ សំផន។

**ការឆ្លើយតបវិញទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា និងមេធាវីនាំមុខ**

ក្រុមមេធាវីការពារក្តី នួន ជា អៀង សារី និង ខៀវ សំផន បានឆ្លើយតបវិញទៅនឹងសេចក្តីសន្និដ្ឋានដែលបានធ្វើដោយសហព្រះរាជអាជ្ញា និងមេធាវីនាំមុខ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- សម្រេចថាលោកស្រីចៅក្រម Fenz នឹងជំនួសលោកស្រីចៅក្រម Cartwright អនុលោមទៅតាមដីកាសម្រេចចុះថ្ងៃទី ១៩ កុម្ភះ ២០១៣។

- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំជនជាប់ចោទ ខៀវ សំផន មកកាន់សាលសវនាការ និង អៀង សារី មកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ឱ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃព្រហស្បត្តិ៍ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលទុឡ្លី** Matteo CRIPPA